The Bible Story in Fear-Power Language ( Khmer )—from www.HonorShame.com

# រឿងក្នុងព្រះគម្ពីរអំពីភាពភ័យខ្លាច និងអំណាច

កាលដើមដំបូងឡើយ ព្រះជាម្ចាស់បានបង្កើតពិភពលោកឡើងដោយអំណាចនៃព្រះបន្ទូលរបស់ទ្រង់។ ព្រះជាម្ចាស់គង់នៅគ្រប់ទីកន្លែងទាំងអស់ជាមួយរបស់ទ្រង់បានបង្កើតមកទាំងនៅស្ថានសួគ៌ និងផែនដី។ ដោយសារសេចក្តីស្រឡាញ់ទ្រង់គ្រប់គ្រងដោយភាពដាច់ខាត និងអំណាច និងគ្រប់ទាំងអ្វីៗទាំងអស់ដែលទ្រង់បង្កើតមសរសើរ ព្រះចេស្តារដ៏មហិមារបស់ទ្រង់។

ដោយសារទ្រង់បានធ្វើអោយផែនដីនេះជាអាណាចក្ររបស់ព្រះអង្គ ព្រះជាម្ចាស់បានចាត់តាំងអ័ដាមអោយក្លាយជាអ្នកមើលការខុសត្រូវរបស់ដែលទ្រង់បានបង្កើតមក។ អ័ដាមជាអ្នកមើលការខុសត្រូវរបស់ព្រះ ហើយក្លាយជារាជបុត្រនៃការបង្កើត។ គាត់ទទួលបានសិទ្ធក្នុងការគ្រប់គ្រងលើរបស់ដែលព្រះជាម្ចាស់បានបង្កើតមក អាចបញ្ជាក់បានតាមរយៈសិទ្ធិក្នុងការដាក់ឈ្មោះអោយសត្វផងទាំងពួងរបស់គាត់។ ក្នុងនាមជាស្តេចដ៏មានរិទ្ធានុភាព ព្រះជាម្ចាស់ទ្រង់តែងតាំងមនុស្សដើម្បីគ្រប់គ្រងផែនដីរបស់ទ្រង់។

ស្រាប់តែនៅពេលមួយមេនៃពួកទេវតាម្នាក់បានបះបោរប្រឆាំងជាមួយព្រះជាម្ចាស់ដែលគ្រប់គ្រងលើទាំងអស់ដោយព្រះចេស្តាទ្រង់។ សាតាំងជាមារសត្រូវដឹកនាំការប៉ះបោរនេះ។ អារក្សមានកល្បិចក្នុងការពង្រីកអំណាចខុសច្បាប់របស់វានៅលើផែនដីនេះដោយយកមនុស្សដាក់អោយនៅក្រោមការគ្រប់គ្រងរបស់វា។សត្វពស់ដែលបានប្រែខ្លួនបានមកលបួងលោមអ័ដាមនិងអេវ៉ាអោយចាកចេញពីព្រះរាជរបស់ព្រះចូលទៅក្នុងការគ្រប់គ្រងរបស់វា។កម្លាំងនៃការបះបោរបានធ្វើអោយមនុស្សស្ថិតនៅក្រោមអំណាចរបស់វា។ក្រុមគ្រួសាររបស់អ័ដាមបានបាត់បង់នូវឋានៈរបស់ខ្លួនដែលធ្លាប់មានអំណាចក្នុងការគ្រប់គ្រងនៅផែនដីនេះ។

ឥឡូវនេះសាតាំងជាអ្នកគ្រប់គ្រងផែនដីនេះវិញម្តង។វាក្លាយជារាជបុត្រថ្មីហើយយើងកើតមកក្នុងអាណា

ចក្ររបស់វា។ភ្នែករបស់មនុស្សគ្រប់គ្នាត្រូវបានងងឹតចំណែកឯចិត្តរបស់គេវិញត្រូវបានសាតាំងឆក់យកទៅបាត់អំពើរបាបការវាយប្រហារខាងវិញ្ញាណនិងការថ្វាយបង្គំរូបព្រះនាំព្រលឹងមនុស្សចូលទៅក្នុងអំណាចនៃភាពងងឹង។ដើម្បីទាមទារនូវអធិបតេយ្យភាពសម្រាប់នគរទ្រង់ឡើងវិញព្រះជាម្ចាស់បានជ្រើសរើសជនជាតិអ៊ីស្រាអែលធ្វើជាឧបករណ៍ពិសេសរបស់ទ្រង់សម្រាប់ចម្បាំងខាងឯងវិញ្ញាណ។

តាមរយៈសម្ព័ន្ធមេត្រីជាមួយជនជាតិអ៊ីស្រាអែលព្រះជាម្ចាស់នឹងពង្រីកការគ្រប់គ្រងរបស់ទ្រង់ទៅកាន់គ្រប់ជាតិសាសន៍ទាំងអស់។ នៅពេលដែលជនជាតិអ៊ីស្រាអែលត្រូវបានគេធ្វើបាបនៅក្នុងប្រទេសអេស៊ីប ព្រះជាម្ចាស់ប្រឈមជាមួយព្រះរបស់ជនជាតិអេស៊ីបដើម្បីរំដោះពួកគេចេញពីទាសភាពរបស់ស្តេចផារ៉ោន។ ក្នុងគម្ពីរនិក្ខមនំបានបង្ហាញពីអំណាចរបស់ព្រះជាម្ចាស់ទៅកាន់មនុស្សទាំងអស់។

ព្រះជាម្ចាស់គឺជាអ្នកចម្បាំងដ៏មហិមាដែលមានអំណាចមកពីស្ថានសួគ៌ឈ្នះលើការអាក្រក់ដែលគ្រប់គ្រងនៅផែនដីនេះ។ពេលដែលអ៊ីស្រាអែលទុកចិត្តព្រះទ្រង់បានផ្តល់អោយពួកគេទទួលបានជ័យជំនះសូម្បីពួកគេមានកម្លាំងតិចក៏ដោយ។ប៉ុន្តែជាញឹកញាប់ពួកគេស្វែងរកអំណាចនៅកន្លែងដែលមិនត្រឹមត្រូវ។ជនជាតិអ៊ីស្រាអែលបានចាញ់ការល្បួងព្រះក្លែងក្លាយថ្វាយបង្គំរូបព្រះ ហើយនឹងបានអនុវត្តន៍ថែមទៀត។

ដោយមិនពឹងផ្អែកលើព្រះជាម្ចាស់នៃពិភពលោកទាំងមូលពួកគេបែរជាទៅជាចងសម្ព័នភាពជាមួយព្រះរបស់ជនជាតិកាណាននិងមេដឹកនាំនៃបណ្តាប្រទេសធំៗដើម្បីទទួលបានការធានាចំពោះការការពារនិងព្រះពរ។ហោរាបានប្រកាសនិងបង្ហាញពីឧត្តមភាពរបស់ព្រះមកលើព្រះរបស់ជនជាតិកាណានប៉ុន្តែអ៊ីស្រាអែលនៅតែគ្មានកម្លាំងដើម្បីគេចចេញពីឥទ្ធិពលរបស់សាតាំង។អំណាចនៃការរំដោះរបស់ព្រះជាម្ចាស់កើតមានតាមរយៈអង្គព្រះយេស៊ូ។ ទ្រង់បានចាប់ផ្តើមព្រះរាជរបស់ព្រះដែលមនុស្សបានរងចាំជាយូរមកហើយ

ដោយការទទួលបានអំណាចពេញលេញតាមរយៈព្រះវិញ្ញាណនៃព្រះព្រះយេស៊ូបានបដិសេធការផ្តល់អោយរបស់សាតាំងក្នុងការគ្រប់គ្រងរួមគ្នានិងនៅតែប្តេជ្ញាចិត្តចំពោះបេសកកម្មរបស់ដើម្បីដោះអំណាចរបស់សាតាំងចេញ។ហេតុការណ៍ដែលមិនធ្លាប់កើតឡើងពីមុនមកគឺព្រះយេស៊ូបានរំដោះមនុស្សអោយបានរួចផុតពីចាប់ឃុំឃាំងរបស់សាតាំង។

អំណាចដែលវាគិតថាការសម្លាប់បុត្រារបស់ព្រះគឺវាអាចពង្រឹងអំណាចនៅក្នុងពិភពលោកនេះ។

ផែនការរបស់វាមិនបានសម្រេចឡើយ។ការសុគតរបស់ព្រះយេស៊ូគ្រីស្ទគឺគ្រាន់តែសុគតសម្រាប់កម្លាំងនៃអំពើរអាក្រក់។ឈើឆ្កាងបានដកហូតអំណាច កម្លាំង និងឈ្នះពួកវាជាសាធារណៈ។
បន្ទាប់មកគឺជាការបង្ហាញនូវអំណាចចេស្តាដែលព្រះជាម្ចាស់បានប្រោសព្រះយេស៊ូអោយមានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញពីសេចក្តីស្លាប់ទៅកាន់អំណាច
និងគ្រប់គ្រងលើអ្វីៗទាំងអស់ពេញដោយព្រះចេស្តា។

មនុស្សគ្រប់គ្នាត្រូវបែចេញពីអំណាចនៃសេចក្តីអាក្រក់ពេលនេះ ហើយចុះចូលជាមួយព្រះយេស៊ូជាព្រះ។ អ្នកជឿលើព្រះយេស៊ូនឹងត្រូវបញ្ជូនចេញពីនគរនៃសេចក្តីងងឹតទៅកាន់នគរនៃពន្លឺ។
ព្រះជាម្ចាស់អោយយើងលូតលាស់ជាមួយនឹងព្រះគ្រីស្ទ និងអោយយើងអង្គុយជាមួយទ្រង់នៅនគរស្ថានសួគ៌ ដូច្នេះយើងក៏មានអំណាចនិងគ្រប់គ្រងលើអ្វីៗទាំងអស់ដែរ។ព្រះគុណព្រះបានស្តារយើងទៅកាន់ឋានៈនៃអំណាចនៅលើផែនដីនេះ។ យើងនឹងទទួលមរតកជាមួយនឹងព្រះគ្រីស្ទ។

ដោយសារយើងអាចចូលទៅកាន់ព្រះគ្រប់ពេលវេលា ឥឡូវនេះយើងអាចឈរមាំប្រឆាំងនឹងសាតាំង។ ទោះបីជាសាតាំងបន្តធ្វើជាសត្វតោស្វែងរកចំណីខែលរបស់ព្រះយេស៊ូការពារយើងពីឥទ្ធិពលអាក្រក់របស់វាដោយយើងមានអត្តសញ្ញាណច្បាស់លាស់និងអំណាចពីព្រះបុត្រាដែលទទួលបានការចាក់ប្រេងតាំងពីព្រះបិតា។ ព្រះជាម្ចាស់ប្រទានពរដល់គ្រីស្ទានគ្រប់គ្រានូវរាល់ព្រះពរខាងវិញ្ញាណពីនគរស្ថានសួគ៌ ធ្វើអោយអំពើរធ្មប់
និងការធ្វើតាមវិញ្ញាណផ្សេងៗក្លាយទៅជាឥតបានការ។ក្នុងនាមជាគ្រីស្ទានដែលដើរតាមការដឹកនាំរបស់ព្រះវិញ្ញាណក្នុងសេចក្តីជំនឿនិងសេចក្តីស្រឡាញ់យើងគ្រប់គ្រងលើខ្មាំងសត្រូវនិងដោះទាសភាពនៃអំពើរបាបចេញ។ ការប្រយុទ្ធនឹងត្រូវបានបញ្ចប់នៅពេលដែលព្រះជាម្ចាស់ចាប់ចងកម្លាំងរបស់សាតាំង
និងគ្រប់គ្រងពិភពលោកនេះពីបល្ល័ង្កទ្រង់អស់កល្បជានិច្ចជាមួយនឹងប្រជារាស្ត្រទ្រង់។